ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣០ សលន

# សារលិខិត

## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
## ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥

**- សូមក្រាបថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ**
**- សម្តេច ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី**
**- បងប្អូនជនរួមជាតិ យុវជន យុវនារី និងក្មួយៗសិស្សានុសិស្ស ជាទីស្រឡាញ់រាប់អាន!**

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំព្រះករុណាផ្ទាល់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមសម្តែងនូវសេចក្តីសោមនស្សរីករាយក្រៃលែង ប្រកបដោយមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅ រួមជាមួយនឹងស្មារតីឆន្ទៈគាំទ្រយ៉ាងពេញទំហឹង ចំពោះការរៀបចំ **«ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥»** ដែលត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំ ទាំងនៅក្នុងប្រទេសកម្ពុជា និងតាមបណ្តាប្រទេសនានាលើសកលលោក។ រាជរដ្ឋាភិបាលកម្ពុជា តែងតែចាត់ទុក ទិវាដ៏មានអត្ថន័យមួយនេះ គឺជាថ្ងៃដ៏មានសារៈសំខាន់មួយ ដែលរំលឹកឱ្យយើងទាំងអស់គ្នាបានឃើញពីការប្តេជ្ញាចិត្ត កិច្ចខិតខំប្រឹងប្រែង ស្មារតីមោះមុត និងចលនាជាតិរបស់កម្ពុជា ក្នុងការចូលរួមប្រយុទ្ធប្រឆាំងគ្រឿងញៀននាឆ្នាំកន្លងទៅ តាមគ្រប់រូបភាព វិធីសាស្ត្រ និងយុទ្ធសាស្ត្រ សំដៅធ្វើយ៉ាងណាកាត់បន្ថយនិងឈានដល់ការលុបបំបាត់បញ្ហាគ្រឿងញៀនចេញពីសង្គមកម្ពុជា។ កម្ពុជា ពិតជាមានមោទនភាពខ្ពស់ ដែលត្រូវបានទទួលការវាយតម្លៃពីការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) ជាប្រទេសគំរូមួយក្នុងការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនកាលពីឆ្នាំ២០២៤ កន្លងទៅ ដែលមានលក្ខណៈអធិកអធម ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិទូទាំង ២៥ រាជធានី ខេត្ត។

សម្រាប់ខ្លឹមសារស្នូលនៃទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនឆ្នាំ២០២៥នេះ ការិយាល័យ UNODC គឺបានផ្តោតសំខាន់ទៅលើវិធានការបង្ការ ការពារ ទប់ស្កាត់ ដើម្បីឈានទៅការកាត់ផ្តាច់ឫសគល់និងវិវដ្តនៃបញ្ហាគ្រឿងញៀន ដោយក្នុងនោះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចកំណត់យកប្រធានបទនៃទិវាសម្រាប់ឆ្នាំ២០២៥ នេះ គឺ **«រួមគ្នា បង្ការ ទប់ស្កាត់ និងកាត់ផ្តាច់ឫសគល់នៃបញ្ហាគ្រឿងញៀននៅកម្ពុជា»** ក្នុងគោលដៅសំដៅធ្វើយ៉ាងណាបំផុសជាចលនាជាតិមួយ ដែលមានការចូលរួមពីគ្រប់វិស័យ ក្នុងការលើកកម្ពស់ការអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងមានវិធានការម៉ឺងម៉ាត់ដាច់ខាតពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ដើម្បីឈានដល់ការកាត់ផ្តាច់ឫសគល់នៃបញ្ហា និងទប់ស្កាត់ការវិលត្រលប់មកវិញនៃបញ្ហាគ្រឿងញៀន ដែលស្របទៅនឹងពាក្យស្លោកជាភាសាអង់គ្លេសរបស់អង្គការសហប្រជាជាតិសម្រាប់ទិវាអន្តរជាតិឆ្នាំ២០២៥ នេះ គឺ BREAK THE CYCLE (កាត់ផ្តាច់ការវិវដ្តនៃបញ្ហាគ្រឿងញៀន)។

ជាការពិត ស្ថានភាពគ្រឿងញៀននៅលើសកលលោក គឺបានកំពុងធ្លាក់ក្នុងសភាពមួយដែលមានលក្ខណៈស្មុគស្មាញ ប្រទាក់ក្រឡា បង្កើតបានជាបញ្ហាវិលទៅវិលមក ប្រៀបដូចជាវដ្តមួយដែលមិនអាចកាត់ផ្តាច់បាន ព្រមទាំងផ្សារភ្ជាប់ទៅនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង បង្កបានជាបទល្មើសច្រើនប្រភេទ និងភាពអសន្តិសុខ ញាំញី បំផ្លិចបំផ្លាញសុខុមាលភាពសង្គមជាតិ ដែលជាឧបសគ្គរាំងដល់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចជាតិ។ ដោយពិនិត្យឃើញមហន្តរាយដែលបណ្តាលមកពីឧក្រិដ្ឋកម្មគ្រឿងញៀននេះ ការិយាល័យ UNODC រួមទាំងប្រទេសកម្ពុជាដែលជាសមាជិកនៃអនុសញ្ញា និងពិធីសារស្តីពីគ្រឿងញៀនរបស់អង្គការសហប្រជាជាតិ បានរួបរួមគ្នាសម្រេចដាក់ចេញនូវប្រធានបទទិវាឆ្នាំនេះ ដែលឈរលើទស្សនវិស័យមួយ គឺការចាត់ទុកបញ្ហាគ្រឿងញៀនគឺជាបញ្ហារួមរបស់យើងទាំងអស់គ្នា ដែលចាប់ផ្តើមចេញពីសមាជិកគ្រួសារម្នាក់ៗរហូតដល់សង្គមទាំងមូល ត្រូវមានការកិច្ចចូលរួម បង្ការ ទប់ស្កាត់ ដើម្បីកាត់ផ្តាច់បញ្ហាដ៏រ៉ាំរ៉ៃមួយនេះចេញពីសង្គមកម្ពុជា។

នៅក្នុងឆ្នាំ២០២៤ កន្លងទៅ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំពូនជ្រំបន្តរក្សាកេរដំណែលគោលនយោបាយដ៏មុតស្រួចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី បច្ចុប្បន្នជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា គឺការតម្កល់ការប្រយុទ្ធប្រឆាំងគ្រឿងញៀនជាទិសដៅអាទិភាពចម្បង រួមនឹងមរតកអភិក្រម **«ផ្ទះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់»** តាមរយៈការដាក់ចេញនូវវិធានការមុតស្រួចដូចជាគោលការណ៍**«សម្អាតផ្ទះយើង»** និងគោលការណ៍**«សម្អាតចកចេញពីផ្ទៃបឹង»** ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ ភាពស្អាតស្អំ និងគំរូនៃការអនុវត្តច្បាប់។ លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជាដែលមានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនជាសេនាធិការ បានដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រ និងវិធីសាស្ត្រថ្មីៗជាច្រើន ដើម្បីកៀរគរឱ្យសង្គមជាតិទាំងមូលចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងយុទ្ធនាការបោសសម្អាតនិងយកបញ្ហាគ្រឿងញៀនចេញពីសហគមន៍។ ជាក់ស្តែងនៅឆ្នាំកន្លងទៅ ការចូលរួមលើកកម្ពស់ការអប់រំពីផលប៉ះពាល់និងវិនាសកម្មនៃគ្រឿងញៀន ត្រូវបានចូលរួមយ៉ាងសកម្មផុសផុលពីសំណាក់យុវជន យុវនារី សិស្សនិស្សិត កម្មករ កម្មការិនី សិល្បករ សិល្បការិនី និងកីឡាករ កីឡាការិនី ដែលទាំងនេះ បង្កើតបានជាចលនាជាតិនិងស្មារតីរួមមួយ ដែលដាស់ស្មារតីដល់យុវវ័យកម្ពុជាគ្រប់រូបមានជំនឿមុតមាំថា ខ្លួននឹងមិនធ្លាក់ក្នុងអន្ទាក់ភ្នក់ភ្លើងនៃគ្រឿងញៀនជាដាច់ខាត ដើម្បីជាការកសាងមូលធនមនុស្សរឹងមាំសម្រាប់អភិវឌ្ឍសង្គមជាតិ។

ជាមួយនឹងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ រាជរដ្ឋាភិបាលកម្ពុជាក៏បានពង្រឹងការធ្វើបរិវត្តកម្មឌីជីថលយ៉ាងសកម្មផុសផុល ដោយក្នុងនោះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបង្កើតជាថ្នាលឌីជីថលដ៏មានសារៈសំខាន់មួយ គឺកម្មវិធីទូរស័ព្ទដៃ NoDrug ដែលជាវិធីសាស្ត្រអប់រំបែបឌីជីថលទាន់សម័យនិងជាបណ្ណំនូវមេរៀន ខ្លឹមសារ និងព័ត៌មានពាក់ព័ន្ធនឹងគ្រឿងញៀន ជាពិសេស ក៏ជាមធ្យោបាយរាយការណ៍ដ៏មានប្រសិទ្ធភាព ២៤ ម៉ោង និងរក្សាការសម្ងាត់សម្រាប់ប្រជាពលរដ្ឋជូនដំណឹងអំពីករណីចែកចាយនិងប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍ ដោយកន្លងទៅប្រជាពលរដ្ឋបានរាយការណ៍ជិត ១៤០០ ករណី ហើយសមត្ថកិច្ចមូលដ្ឋានបានសហការដោះស្រាយបង្ក្រាបបានជិត ១២០០ ករណី ដែលនេះសបញ្ជាក់ឱ្យឃើញពីការចូលរួមសហការគ្នារវាងប្រជាពលរដ្ឋនិងកម្លាំងអនុវត្តច្បាប់ក្នុងការយកបញ្ហាគ្រឿងញៀនចេញពីសហគមន៍។ ទោះបីជាវិធានការបង្ការ ទប់ស្កាត់ និងអប់រំ ជាទិសដៅអាទិភាពក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនក៏ពិតមែន ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាក៏មិនមានការបន្ធូរបន្ថយដល់វិធានការអនុវត្តច្បាប់នោះដែរ ជាក់ស្តែងនៅក្នុងឆ្នាំ២០២៤ កន្លងទៅ កម្លាំងនគរបាលជាតិ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានបើកប្រតិបត្តិការយ៉ាងសស្រាក់សស្រាំក្រោមស្មារតីមោះមុតជាទីបំផុត ក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀនជាច្រើនករណី និង

បានឃាត់ខ្លួនជនសង្ស័យ ព្រមទាំងកសាងសំណុំរឿងបញ្ជូនទៅតុលាការ និងបានចាត់វិធានការយ៉ាងតឹងរ៉ឹងក្នុងការត្រួតពិនិត្យ ទប់ស្កាត់លំហូរចូលគ្រឿងញៀនពីបរទេស ទាំងតាមមធ្យោបាយផ្លូវគោក ទឹក អាកាស និងបញ្ញើប្រៃសណីយ៍។

គោលការណ៍រួមរបស់រាជរដ្ឋាភិបាលកម្ពុជា **គឺសំដៅធ្វើយ៉ាងណាខិតខំបញ្ចៀសឱ្យបាន មិនឱ្យកម្ពុជាក្លាយជាគោលដៅនៃការប្រព្រឹត្តបទល្មើសគ្រឿងញៀន និងមិនឱ្យបញ្ហាគ្រឿងញៀនជះឥទ្ធិពលបំផ្លិចបំផ្លាញដល់សង្គមជាតិ** ដោយត្រូវធ្វើយ៉ាងណាកាត់ផ្តាច់ការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍ តាមរយៈវិធានការអប់រំ បង្ការ ទប់ស្កាត់ និងកាត់ផ្តាច់ឱ្យបានដល់ឫសគល់នៃបញ្ហាគ្រឿងញៀន ដោយឈរលើទស្សនវិស័យ **«ចូលរួមទាំងអស់គ្នា ដើម្បីជីវិតនិងសហគមន៍គ្មានគ្រឿងញៀន»**។

**ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ និងបងប្អូនជនរួមជាតិទាំងអស់ជាទីគោរពស្រឡាញ់!**

ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន គឺពុំអាចចាត់ទុកជាសមត្ថកិច្ចផ្តាច់មុខរបស់ស្ថាប័នឬអង្គភាពណាមួយឡើយ ប៉ុន្តែគឺជាកាតព្វកិច្ចរួមរបស់ប្រជាពលរដ្ឋកម្ពុជាយើងទាំងអស់គ្នា ដែលយើងម្នាក់ៗសុទ្ធតែមានភារកិច្ចរៀងៗខ្លួន តាមរយៈការចូលរួមផ្សព្វផ្សាយ អប់រំ អំពីវិនាសកម្មនៃគ្រឿងញៀន និងការប្រកាន់គោលជំហរដាច់ខាតពេញមួយជីវិត គឺមិនពាក់ព័ន្ធនឹងការប្រើប្រាស់និងជួញដូរគ្រឿងញៀន។ ក្នុងន័យនេះ ការចូលរួមពីគ្រប់វិស័យទាំងអស់ ដូចជាវិស័យអប់រំ សាសនា វប្បធម៌ កីឡា សិល្បៈ ទាំងរដ្ឋនិងឯកជន រួមទាំងអង្គការជាតិនិងអន្តរជាតិនានា គឺពិតជាកម្លាំងចលករដ៏ខ្លាំងក្លាមួយមិនអាចខ្វះបាន ដែលជួយជំរុញឱ្យរាជរដ្ឋាភិបាលកម្ពុជាសម្រេចបានជោគជ័យជាផ្លែផ្កា ក្នុងបេសកកម្មដ៏មានសារៈសំខាន់មួយនេះ។

ដើម្បីឆ្លើយតបទៅនឹងអត្ថន័យនៃទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥ ដែលមានប្រធានបទ **«រួមគ្នា បង្ការ ទប់ស្កាត់ និងកាត់ផ្តាច់ឫសគល់នៃបញ្ហាគ្រឿងញៀននៅកម្ពុជា»** តាងនាមរាជរដ្ឋាភិបាលកម្ពុជា ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមធ្វើការអំពាវនាវនិងណែនាំដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ដូចតទៅ៖

១. បន្តស្មារតីរួមនិងចលនាជាតិមួយក្នុងការចូលរួមផ្សព្វផ្សាយ អប់រំ ឱ្យបានទូលំទូលាយដល់គ្រប់មូលដ្ឋានទូទាំងប្រទេស អំពីផលប៉ះពាល់និងវិនាសកម្មនៃគ្រឿងញៀន និងបង្កើនភាពជឿជាក់សម្រាប់រាល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបថា **«មួយជីវិតគឺមិនពាក់ព័ន្ធនឹងគ្រឿងញៀន»**។

២. លើកទឹកចិត្តប្រជាពលរដ្ឋទាំងអស់ ជាពិសេស យុវជននិងយុវនារី ទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលជាបណ្តុំនៃមេរៀន សារអប់រំ ព័ត៌មាន សេវាព្យាបាលនិងស្តារនីតិសម្បទា ជាពិសេស ជាមធ្យោបាយរាយការណ៍ដ៏រហ័សនិងសម្ងាត់អំពីករណីប្រើប្រាស់និងចែកចាយគ្រឿងញៀនក្នុងសហគមន៍។ ការប្រើប្រាស់ App NoDrug គឺស្មើនឹងចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅកម្ពុជា។

៣. គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបន្តធ្វើជាគំរូនៃភាពស្អាតស្អំ និងអភិបាលកិច្ចល្អតាមរយៈការធ្វើតេស្តរកសារធាតុញៀន ចំពោះមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធជាប់ជាប្រចាំ និងមានវិធានការម៉ឺងម៉ាត់តាមបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១បប ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងលើកទឹកចិត្តដល់វិស័យឯកជននានាដែលស្ម័គ្រចិត្តចូលរួមអនុវត្តបទបញ្ជានេះ។

៤. អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងគណៈបញ្ជាការឯកភាពរាជធានី ខេត្ត ត្រូវបន្តពង្រឹងតួនាទីភារកិច្ច ក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន កាត់ផ្តាច់ឬសគល់មេក្លោង និងលុបបំបាត់ទីផ្សារគ្រឿងញៀន ជាពិសេស ទប់ស្កាត់ខ្សែរយៈចែកចាយទៅក្នុងសហគមន៍ និងជនបទ ដោយឈរលើគោលការណ៍ «**៣កុំ ១រាយការណ៍**» គឺកុំពាក់ព័ន្ធ កុំអន្តរាគមន៍ កុំលើកលែង និងត្រូវរាយការណ៍។

៥. រដ្ឋបាលរាជធានី ខេត្ត ត្រូវម្ចាស់ការលើការងារផ្សព្វផ្សាយអប់រំ ដោយត្រូវបញ្ជ្រាបការអប់រំអំពីផលប៉ះពាល់ និងវិនាសកម្មនៃគ្រឿងញៀន ឱ្យចំគោលដៅហានិភ័យនៅក្នុងមូលដ្ឋានតាមក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ និងរៀបចំរបៀបរៀបរយសណ្តាប់ធ្នាប់បរិវេណជុំវិញសាលារៀនឱ្យបានល្អប្រសើរ **ដោយគ្មានការប្រើប្រាស់គ្រឿងញៀន**។

៦. លើកទឹកចិត្តឱ្យវិស័យឯកជនទាំងអស់ ចូលរួមវិនិយោគជាមួយរាជរដ្ឋាភិបាល លើការងារលើកកម្ពស់ការផ្សព្វផ្សាយអប់រំអំពីបញ្ហាគ្រឿងញៀន តាមគ្រប់មធ្យោបាយនិងគ្រប់រូបភាព។

៧. លើកទឹកចិត្តឱ្យគ្រប់ព្រឹត្តិការណ៍នានា ដូចជាព្រឹត្តិការណ៍សិល្បៈ តន្ត្រី កីឡា វប្បធម៌ និងសាសនា ក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយនានា សូមឱ្យមានបង្កប់សារដាស់តឿននិងអប់រំឱ្យប្រជាពលរដ្ឋជៀសឆ្ងាយពីគ្រឿងញៀន។

៨. លើកទឹកចិត្ត មាតា បិតា អាណាព្យាបាល និងសាមីខ្លួនអ្នកញៀន ត្រូវមានស្មារតីរឹងមាំក្លាហានក្នុងការទទួលយកសេវាបន្សាប ព្យាបាល និងស្តារនីតិសម្បទា នៅតាមមជ្ឈមណ្ឌលនិង/ឬមណ្ឌលរដ្ឋនិងឯកជន ដើម្បីចូលរួមកសាងធនធានមនុស្សឡើងវិញសម្រាប់សង្គមជាតិ។

៩. ផ្សព្វផ្សាយ អប់រំ និងណែនាំឱ្យបានទូលំទូលាយដល់សិស្សានុសិស្សកុំឱ្យប្រើប្រាស់បារីអេឡិចត្រូនិក វេប ស៊ីហ្សា ដែលអាចប៉ះពាល់ដល់សុខភាពនិងប្រព័ន្ធប្រសាទរបស់យុវវ័យដែលជាទំពាំងស្នងឫស្សី។

ឆ្លៀតក្នុងឱកាសនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងអំណរគុណដល់ជនរួមជាតិទាំងអស់ ជាពិសេសថ្នាក់ដឹកនាំ មន្ត្រីជំនាញ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមគាំទ្រជាមួយរាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ហើយខ្ញុំសង្ឃឹមនិងជឿជាក់យ៉ាងមុតមាំថា គ្រប់ភាគីពាក់ព័ន្ធទាំងអស់នឹងបន្តសហការចូលរួមឧបត្ថម្ភគាំទ្រនិងអនុវត្តយុទ្ធនាការនានា ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល ដើម្បីគាំទ្រដល់ចលនាប្រយុទ្ធប្រឆាំងគ្រឿងញៀននៅកម្ពុជា។

ជាទីបញ្ចប់ ជាមួយនឹងឱកាសនៃការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥ នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមប្រគេនពរថ្វាយសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ និងសូមជូនពរដល់ សម្តេច ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី និងបងប្អូនជនរួមជាតិទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**